**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

លេខៈ ០០៦ របក អ.ជ.ប.គ.ញ

ថ្ងៃចន្ទ ១៣ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ឆ្នាំ២០២៦

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ.)ជាស្ថាប័នអនុវត្តគោលនយោបាយនិងជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ជាពិសេសទិសដៅការងារដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២៦ ដោយសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០២៥ និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជាសមាជិក ព្រមទាំងមានការចូលរួម និងគាំទ្រពីវិស័យឯកជន វិស័យសាសនា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋពីគ្រប់មជ្ឈដ្ឋានផងនោះ បានអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់តាមគោលការណ៍ «**សម្អាតផ្ទះយើង**» និងគោលការណ៍ «**សម្អាតចកចេញពីផ្ទៃបឹង**» សំដៅលើកកម្ពស់ប្រសិទ្ធភាពការងាររួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសង្គម និងកសាងធនធានមនុស្សប្រកបដោយសក្តានុពលសម្រាប់ជាតិ ហើយទទួលបាននូវលទ្ធផលជាក់ស្តែងគួរជាទីមោទនៈ ដូចខាងក្រោមៈ

## I. សភាពការណ៍គ្រឿងញៀន

### ក. សភាពការណ៍គ្រឿងញៀនសកល

ស្របពេលដែលបរិបទសកលលោកនាពេលបច្ចុប្បន្ន បាននិងកំពុងស្ថិតក្នុងស្ថានភាព មានហានិភ័យខ្ពស់ ភាពផុយស្រួយនិងមិនប្រាកដប្រជាដែលពិបាកស្មាន ការញាំញីទៅដោយសង្គ្រាមនិងជម្លោះតាមតំបន់ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយដ៏តានតឹង និងការបន្តធ្លាក់ចុះនូវសណ្តាប់ធ្នាប់ពិភពលោក ជារួមក្នុងស្ថានការណ៍មិនអំណោយផលដូចនេះ ក៏ជាហេតុបច្ច័យដ៏អាក្រក់បង្កជាឱកាសដល់ក្រុមឧក្រិដ្ឋជនបង្កើនសកម្មភាព ពង្រីកបណ្តាញឧក្រិដ្ឋកម្ម និងបង្កើតចេញនូវយុទ្ធសាស្ត្រ កលល្បិចថ្មីៗក្នុងការប្រព្រឹត្តបទល្មើសគ្រប់ប្រភេទ **ជាពិសេសបទល្មើសគ្រឿងញៀន**។ ជាក់ស្តែង ក្រុមឧក្រិដ្ឋជនគ្រឿងញៀនបានឆ្លៀតឱកាសបង្កើនការជំរុញ និងផលិតគ្រឿងញៀន ក៏ដូចជាលួចលាក់ចរាចរសារធាតុគីមីផ្សំខុសច្បាប់ ដែលមានសកម្មភាពរីករាលដាលទាំងនៅក្នុង



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

ក្របខ័ណ្ឌតំបន់ អន្តរជាតិ ជាពិសេសតំបន់ត្រីកោណមាស។ ជាមួយគ្នានេះ គ្រប់សកម្មភាពនៃបទល្មើសគ្រឿងញៀន នាពេលបច្ចុប្បន្ន បានប្រព្រឹត្តទៅក្នុងរូបភាពជាក្រុមជនប្រដាប់អាវុធ មានអង្គការចាត់តាំង មានបណ្តាញចាក់ស្រេះ និងកម្លាំងរឹងមាំដែលពិបាកក្នុងការបង្ក្រាបឱ្យបានដល់ឫសគល់។

### ២. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ស្ថិតក្នុងស្ថានភាពនៃបទល្មើសគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិដូចខាងលើ កម្ពុជាក៏នៅតែបន្តរងការគំរាមកំហែងពីនិន្នាការជាសកលទាំងនោះ ជាពិសេសការរងឥទ្ធិពលគ្រឿងញៀនពីតំបន់ត្រីកោណមាស។ តាមរយៈលទ្ធផលនៃកិច្ចប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនរបស់កម្លាំងអនុវត្តច្បាប់ ក្នុងរយៈពេល៦ខែ ឆ្នាំ២០២៦នេះ បានបង្ហាញឱ្យឃើញថា គ្រឿងញៀនដែលចរាចរចូលតាមច្រកព្រំដែនគោក មានប្រមាណ **៨៤,៦៣%** (ករណីចរាចរឆ្លងកាត់តាមច្រកព្រំដែនឡាវ ប្រមាណ ៨៤,៤% និងករណីចរាចរឆ្លងកាត់តាមច្រកព្រំដែនថៃ ប្រមាណ ០,២៣%) តាមបញ្ញើប្រៃសណីយ៍ប្រមាណ **០,២២%** ករណីកែច្នៃផលិតប្រមាណ **៧,៦០%** និងករណីរក្សាទុក ជួញដូរ ចាត់ចែង សម្រួលឱ្យប្រើប្រាស់ប្រមាណ **៧,៥៤%**។

ក្រៅពីការកត់សម្គាល់លើសភាពការណ៍គ្រឿងញៀនខាងលើ ក្នុងក្របខ័ណ្ឌនៃការចាត់តាំងអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ក៏អាចវាយតម្លៃបានថា ការងារផ្សព្វផ្សាយ អប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ត្រូវបានធ្វើសកម្មភាពជាប្រចាំ និងមានការកើនឡើងច្រើនបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក៏បានអនុវត្តកាន់តែសកម្មនិងមានប្រសិទ្ធភាពជាងមុន ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ត្រូវបានអនុវត្តជាប្រចាំដោយធ្វើកិច្ចសន្យាមិនឱ្យមានជួញដូរ និងប្រើប្រាស់គ្រឿងញៀនក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ហើយកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ ដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា ការផ្លាស់ប្តូរព័ត៌មាននិងចែករំលែកបទពិសោធទៅវិញទៅមកជាត្រូវបានពង្រឹងនិងពង្រីកបន្តបន្ទាប់។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** បានបន្តប្រមូលផ្តុំដឹកនាំនិងជំរុញការចាត់តាំងអនុវត្តអនុសាសន៍ណែនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២៦ ក្នុងនោះគឺការខិតខំអនុវត្តឱ្យបានល្អនូវទិសដៅអាទិភាពទាំង៦ឱ្យទទួលបានជោគជ័យ ដែលអាចសម្រេចបាននូវគោលដៅដ៏ពិសិដ្ឋក្នុងការកាត់បន្ថយ និងលុបបំបាត់បញ្ហាគ្រឿងញៀនចេញពីសង្គមកម្ពុជា រួមទាំងអនុសាសន៍ណែនាំ៧ចំណុចនៃបេសកកម្មដ៏មានអត្ថន័យ គឺការកសាងសហគមន៍មួយដែលគ្រឿងញៀនលែងជាឧបសគ្គនៃការអភិវឌ្ឍជាតិ ជាពិសេសគឺការបង្ហាញឆន្ទៈមោះមុត និងទស្សនវិស័យច្បាស់លាស់របស់រាជរដ្ឋាភិបាល ក្នុងការ**រួមគ្នាឆ្លើយតបបញ្ហាគ្រឿងញៀនក្នុងបរិបទថ្មីប្រកបដោយភាពច្នៃប្រឌិត**។

### ១. ការផ្សព្វផ្សាយ អប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមទាំងក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងភាគីពាក់ព័ន្ធ **បានពង្រឹងប្រសិទ្ធភាពការផ្សព្វផ្សាយ អប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន** ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ និងលើស្លាកផលិតផល**

ក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. និងអង្គភាពពាក់ព័ន្ធ រួមទាំងជាមួយវិស័យឯកជន បានធ្វើការផ្សព្វផ្សាយ អប់រំតាមគ្រប់មធ្យោបាយ គ្រប់រូបភាព និងគ្រប់ទីកន្លែង ក្នុងនោះមានជាអាទិ៍៖

– ការផ្សព្វផ្សាយ អប់រំ តាមកម្មវិធីទូរស័ព្ទដៃ NoDrug ដែលជាមធ្យោបាយសម្រាប់តភ្ជាប់រវាងមហាជនជាមួយសមត្ថកិច្ចក្នុងការចូលរួមបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀននៅតាមសហគមន៍

– ផ្តល់បទសម្ភាសន៍ស្តីពីគ្រឿងញៀន តាមរយៈវិទ្យុ ទូរទស្សន៍រដ្ឋ និងឯកជន បានយ៉ាងផុលផុស

– បញ្ចូល និងបញ្ជូនសារអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងផលិតផលភាពយន្ត ទូរស័ព្ទចល័ត ព័ត៌មានអេឡិចត្រូនិក សៀវភៅព្រឹត្តិបត្រ និងផ្សព្វផ្សាយជាឃ្លីបវីដេអូខ្លី ស្តីពីគ្រឿងញៀន នៅក្នុងគេហទំព័រ Facebook Page វិក្កយបត្រអគ្គិសនី និងការដាក់សារលើស្លាកផលិតផល ក្នុងនោះមានជាអាទិ៍៖

- គេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានអ្នកចូលអាន **៨៤០.៦៦៦ ដង** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១៧៦.២៨៧ ដង) ច្រើនជាង **៦៦៤.៣៧៩ ដង**
- ក្រុមហ៊ុនទូរស័ព្ទចល័តទាំង៤ (Viettel, Smart, CamGSM និងSEATEL) បានបញ្ជូនសារអប់រំពីគ្រឿងញៀនទៅកាន់ទូរស័ព្ទដៃ **២០៨.៤២០.៨០៥ ដង** លើស៊ីមកាតដែលបានលក់ចេញក្នុងឆមាសទី១ (២១.៧១៦.៦៥៤ស៊ីម) ធៀបនឹងចំនួនសារដែលបានបញ្ជូនចេញក្នុងឆមាសទី១ឆ្នាំ២០២៥ (១០៨.៥២៦.៨៧៧ ដង) ច្រើនជាង ៩៩.៨៩៣.៩២៨ ដង កើនលើស **៩២% (មានលម្អិតក្នុងឧបសម្ព័ន្ធទី១)**
- ការដាក់សារអប់រំលើស្លាកផលិតផលនូវពាក្យស្លោក «គ្រឿងញៀននាំមកនូវគ្រោះថ្នាក់ដល់សុខភាព»បានចំនួន **២.៩៨៥ ផលិតផល** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១.២៥៦ ផលិតផល) កើនលើស **១៣៧,៦%**
- ស្ថានីយវិទ្យុ ទូរទស្សន៍ជាតិ ព័ត៌មានជាភាសាខ្មែរ និងភាសាបរទេស ការផលិតស្ប៉ុតពាក្យស្លោកអប់រំពីគ្រឿងញៀន និងព្រឹត្តិបត្រព័ត៌មាន គេហទំព័រ Facebook Page។ល។ **(មានលម្អិតក្នុងឧបសម្ព័ន្ធទី១)**

**១.២ ការផ្សព្វផ្សាយ អប់រំនៅតាមសហគមន៍**

ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារផ្សព្វផ្សាយ អប់រំ នៅតាមសហគមន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់ បង្កើតបានជាចលនាជាតិលេចធ្លោក្នុងស្មារតីរួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើឱ្យមានអ្នកដែលបានចូលរួមនៅក្នុងវិស័យនេះ សរុប **១៤.៥៨០.៨៦០** អង្គ/នាក់ (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១៣.៣១១.៨០២ អង្គ/នាក់) ច្រើនជាង ១.២៦៩.០៥៨ អង្គ/នាក់ **កើនលើស ៩,៥៣%** (ក្នុងម្នាក់ៗអាចបានចូលរួមលើសពី១ដង) ក្នុងនោះមានជាអាទិ៍៖

– មហាជនប្រមាណជាង **៦លាននាក់** បានទទួលសារអប់រំអំពីបញ្ហាគ្រឿងញៀន តាមរយៈសកម្មភាពផ្សេងៗរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត

– ក្រសួង ស្ថាប័ន បានផ្សព្វផ្សាយ អប់រំពីបញ្ហាគ្រឿងញៀនទៅតាមវិស័យជំនាញរបស់ខ្លួនចំនួន **១៥.០៧៣ លើក** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១១.៧៤៥ លើក) ច្រើនជាង ៣.៣២៨ លើក **កើនលើស ២៨,៣%** ដោយគ្របដណ្តប់អ្នកដែលបានទទួលសារអប់រំចំនួន **២.៣៥៧.៥៧៨ នាក់** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៣.៨១៨.៦០២ នាក់) តិចជាង ១.៤៦១.០២៤ នាក់ **ថយចុះ ៣៨,២% (លម្អិតក្នុងឧបសម្ព័ន្ធទី១)**

– គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានផ្សព្វផ្សាយ អប់រំបញ្ហាគ្រឿងញៀន បានចំនួន **១០៦.៧៩៣ លើក** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៧៤.០៧៣ លើក) ច្រើនជាង ៣២.៧២០ លើក **កើនលើស ៤៤,១%** ដោយគ្របដណ្តប់លើអ្នកដែលបានទទួលសារអប់រំចំនួន **៦.២១៧.២៨២ នាក់** (នៅឆមាសទី១ ឆ្នាំ២០២៥ មានចំនួន ៣.៤៨៥.៧០០ នាក់) ច្រើនជាង ២.៧៣១.៥៨២ នាក់ **កើនលើស ៧៨,៣% (មានលម្អិតក្នុងឧបសម្ព័ន្ធទី២)**

– អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ បានប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ ក្រោមអធិបតីភាព **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅសាលមហោស្រពកោះពេជ្រ ដែលមានអ្នកចូលរួម ប្រមាណជាង **៦៣ន់នាក់**

– បានពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ អប់រំ អំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈដៃគូដែលបានចុះMOUជាមួយគ្នា ក៏ដូចជាការបន្តចុះMOUជាមួយស្ថាប័ន អង្គភាព រួមទាំងការបំផុស ចលនាយុវជន និងមហាជនឱ្យចូលរួមកាន់តែសកម្មក្នុងការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន

– ចូលរួមផ្សព្វផ្សាយ អប់រំពីបញ្ហាគ្រឿងញៀនក្នុងពិធីបុណ្យទន្លេលើកទី១០ នៅខេត្តក្រចេះ

– អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានបែងចែកឯកសារ និងសម្ភារសម្រាប់ការផ្សព្វផ្សាយ អប់រំពីបញ្ហាគ្រឿងញៀន។**(លម្អិតក្នុងឧបសម្ព័ន្ធទី៣)**

## ២. ការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានពង្រឹងការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន បានដំណើរការ ជាប្រក្រតី តាមរយៈការផ្តល់ឱសថជំនួសមេតាដូនដល់អ្នកញៀនគ្រឿងញៀនពួកអាភៀន និងការអនុវត្តកម្ម វិធីម្ជុល/សឺរ៉ាំងចំពោះអ្នកញៀនគ្រឿងញៀនដោយចាក់របស់អង្គការដៃគូ។**(មានលម្អិតក្នុងឧបសម្ព័ន្ធទី៤)**

### ២.២. ការពង្រឹងប្រសិទ្ធភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

ការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀនគឺជាសេវាអន្តរាគមន៍ មួយយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រកាត់បន្ថយតម្រូវការគ្រឿងញៀន ជាពិសេសការផ្តាច់គ្រឿងញៀនបានដោយ ជោគជ័យ និងការបញ្ជូនត្រឡប់ទៅក្រុមគ្រួសារឱ្យក្លាយជាពលរដ្ឋល្អនៅក្នុងសហគមន៍។ តាមរយៈយន្តការ នៃការពង្រឹងប្រសិទ្ធភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន យើងទទួលបាននូវលទ្ធផលការងារដូចខាងក្រោម៖

#### ២.២.១. ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

តាមរយៈការងារប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ ឯកជន និងនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈនិង ការចាត់វិធានការលើអ្នកប្រើប្រាស់គ្រឿងញៀនដែលសមត្ថកិច្ចឃាត់ខ្លួនបាន យើងអាចគ្រប់គ្រងបានអ្នកញៀន គ្រឿងញៀន ដែលមានស្ថានភាពដូចខាងក្រោម៖

- អ្នកញៀនគ្រឿងញៀនដែលយើងគ្រប់គ្រងបានជាក់ស្តែងនៅក្នុងឆមាសទី១ ឆ្នាំ២០២៦នេះ មានចំនួន **២២.១៨៣ នាក់** (នៅឆមាសទី១ឆ្នាំ២០២៥ ចំនួន ១៥.០៦២ នាក់) ច្រើនជាង **៧.១២១ នាក់ កើនលើស ៤៧,២%** ដែលក្នុងនោះរួមមាន៖

  - អ្នកញៀនគ្រឿងញៀនដែលមានមុខជាក់ស្តែងនៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន មានចំនួន **១៨.៧៧៨ នាក់** (ដោយបូកបញ្ចូលគ្នារវាងចំនួនអ្នកញៀនដែលសល់ពីចុងឆ្នាំ២០២៥ ហើយបានបន្តស្នាក់នៅក្នុងមជ្ឈមណ្ឌលនាដើមឆ្នាំ២០២៦នេះ មានចំនួន **៨.៧១៦** នាក់ និងអ្នកដែលចូលថ្មីមកទទួលសេវាក្នុងមជ្ឈមណ្ឌលសម្រាប់ឆមាសទី១ដើមឆ្នាំ២០២៦នេះ មានចំនួន **១០.០៦២** នាក់)។ ដោយឡែកនៅក្នុងឆមាសទី១ឆ្នាំ២០២៦នេះផងដែរ អ្នកបានព្យាបាលជាសះស្បើយរួចធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញបានចំនួន **៩.៣៩៥ នាក់** និងអ្នកញៀនគ្រឿងញៀនដែលកំពុងបន្តស្នាក់នៅក្នុងមជ្ឈមណ្ឌលមានចំនួន **៩.៣៨៣ នាក់**

  - អ្នកញៀនគ្រឿងញៀនដែលបានមកទទួលសេវាពិនិត្យ និងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មានចំនួន **២.៦៤៧ នាក់** ក្នុងនោះមន្ទីរពេទ្យបង្អែកមានចំនួន ២.២១៣ នាក់ មណ្ឌលសុខភាពមានចំនួន ៥៩ នាក់ និងមណ្ឌលសុខភាពដែលមានទីតាំងក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន មានចំនួន ៣៧៥ នាក់ (មជ្ឈមណ្ឌលជាតិកែវផុស មានចំនួន ១៧៧ នាក់ និងមជ្ឈមណ្ឌលឱកាសខ្ញុំ មានចំនួន ១៩៨ នាក់)។ **បញ្ជាក់៖** ទិន្នន័យដែលត្រូវបានគិតបញ្ចូលទៅក្នុងចំនួនអ្នកញៀនគ្រឿងញៀនដែលយើងគ្រប់គ្រងបានជាក់ស្តែងនៅក្នុងឆមាសទី១ឆ្នាំ២០២៦នេះ គឺជាចំនួនអ្នកញៀនគ្រឿងញៀនដែលបានមកទទួលសេវាពិនិត្យនិងព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព មានចំនួនសរុប **២.២៧២ នាក់**

  - អ្នកប្រើប្រាស់គ្រឿងញៀនដែលសមត្ថកិច្ចឃាត់ខ្លួន រួចចាត់វិធានការបញ្ជូនទៅតុលាការ មានចំនួន **១.១៣៣ នាក់**។**(មានលម្អិតក្នុងឧបសម្ព័ន្ធទី១ ទី៥និង៧)**

ជាមួយគ្នានេះ នៅក្នុងឆមាសទី១ឆ្នាំ២០២៦៖

- បានសហការសម្របសម្រួលជូនប្រតិភូជាន់ខ្ពស់ក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តស្វាយរៀង និងទស្សនកិច្ចសិក្សាស្វែងយល់នៅមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ

- សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀននៅទូទាំងប្រទេស មានចំនួន **៥៥៦ កន្លែង** ក្នុងនោះ មន្ទីរពេទ្យជាតិ ៣កន្លែង ស្មើនឹង ២៥% មន្ទីរពេទ្យរាជធានី ខេត្ត ២៥កន្លែង ស្មើនឹង១០០% មន្ទីរពេទ្យបង្អែកស្រុក ៨០កន្លែង ស្មើនឹង ៨៣% និងមណ្ឌលសុខភាព ៤៤៨កន្លែង ស្មើនឹង ៣៤% (**លម្អិតក្នុងឧបសម្ព័ន្ធទី១**)

- មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនសរុបមាន **១៨ កន្លែង** (មជ្ឈមណ្ឌលរបស់រដ្ឋ ៦កន្លែង ឯកជន ១០កន្លែង និងអង្គការមិនមែនរដ្ឋាភិបាល ២កន្លែង។(**លម្អិតក្នុងឧបសម្ព័ន្ធទី១**)

### ២.២.២. ការពង្រឹងសមត្ថភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

តាមរយៈយន្តការនៃការពង្រឹងសមត្ថភាពព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌល និងតាមមូលដ្ឋានសុខាភិបាលសាធារណៈ យើងមានសកម្មភាពការងារដូចខាងក្រោម៖

- បានកំពុងជំរុញការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP) សម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

– ពង្រឹងយន្តការគ្រប់គ្រង និងការងារសម្របសម្រួលរបស់ស្ថាប័ន អង្គភាព អង្គការដៃគូ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន នៅទូទាំងប្រទេស

– រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន

– ចុះពិនិត្យ វាយតម្លៃពីវឌ្ឍនភាពការងារ និងការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP) សម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

– បាននិងកំពុងរៀបចំដាក់ឱ្យដំណើរការសាកល្បងនូវថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន។(**មានលម្អិតក្នុងឧបសម្ព័ន្ធទី៦**)

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការសម្របសម្រួលជាមួយស្ថាប័ន អង្គភាពអនុវត្តច្បាប់ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ឈានទៅបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន ដោយបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ ជាពិសេសសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់៖

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានសហការសម្របសម្រួលក្នុងការរៀបចំ និងចូលរួមកិច្ចប្រជុំ សន្និសីទ វគ្គបណ្តុះបណ្តាល ដូចខាងក្រោម៖

– ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃ អ.ជ.ប.គ.ញ. បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO) តាមប្រព័ន្ធអនឡាញ

– សន្និសីទ ស្តីពីប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី២៨ (ADEC-28) ដែលរៀបចំដោយទីភ្នាក់ងារនគរបាលប្រទេសជប៉ុន នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

– កិច្ចប្រជុំបណ្ដាញត្រួតពិនិត្យគ្រឿងញៀនអាស៊ានលើកទី២០ (ADMN) តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបង្ក្រាបគ្រឿងញៀនតាមកំពង់ផែអាស៊ាន (10th ASITF) ដែលរៀបចំដោយគណៈកម្មាធិការកណ្តាលត្រួតពិនិត្យគ្រឿងញៀនមីយ៉ាន់ម៉ា(CCDAC) តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំនៃក្រុមការងារប្រតិបត្តិការមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ(SMCC) សម្រាប់បណ្តាប្រទេសជាសមាជិកទាំង៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំប្រចាំឆ្នាំលើកទី២ ស្តីពីការវិភាគព័ត៌មានសម្ងាត់ពាក់ព័ន្ធបញ្ហាគ្រឿងញៀន ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំប្រចាំឆ្នាំលើកទី១២ របស់មជ្ឈមណ្ឌលព័ត៌មាន និងសម្របសម្រួលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រឿងញៀន(APICC) តាមប្រព័ន្ធអនឡាញ

– វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសស៊ើបអង្កេតជាន់ខ្ពស់ ការគ្រប់គ្រងកន្លែងកើតហេតុ ការឃ្លាំមើល និងការប្រគល់ទទួលដោយមានការឃ្លាំមើល រៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) នៅខេត្តសៀមរាប

- សិក្ខាសាលាអាស៊ាន-ចិន ស្តីពីការពិនិត្យទីកន្លែងបង្ក្រាបគ្រឿងញៀន រៀបចំដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន(NNCC) នៅទីក្រុងយូណាន ប្រទេសចិន

ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.៣. បានរៀបចំពិធីប្រគល់-ទទួលឧបករណ៍សម្ភារបច្ចេកទេស ដែលជាជំនួយរបស់សាធារណរដ្ឋកូរ៉េ របស់មជ្ឈមណ្ឌលព័ត៌មាន និងសម្របសម្រួលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មគ្រឿងញៀន(APICC)។ **(មានលម្អិតក្នុងឧបសម្ព័ន្ធទី៦)**

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន [1]

តាមរយៈកិច្ចប្រតិបត្តិការការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនរបស់កម្លាំងអនុវត្តច្បាប់ នៅក្នុងឆមាសទី១ឆ្នាំ២០២៦នេះ យើងទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- បង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន **៥.៧១៤ ករណី** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៥.១៨២ ករណី) ច្រើនជាង ៥៣២ ករណី **កើនលើស ១០,២%** ក្នុងនោះ៖
  - ករណីជួញដូរ(១០ក្រាមឡើង) ៧៨៨ករណី ឃាត់ខ្លួន ២.២២៤នាក់(ស្រី២៤៨នាក់)
  - ករណីជួញដូរ ដឹកជញ្ជូន រក្សាទុក ២.៤៧៣ករណី ឃាត់ខ្លួន ៥.០០៥នាក់(ស្រី៣៣៧នាក់)
  - ករណីកែច្នៃផលិត ១២ករណី ឃាត់ខ្លួន ៤៨នាក់(ស្រី ៥នាក់)
  - ករណីចាត់ចែង-សម្រួល ១២ករណី ឃាត់ខ្លួន ៥៤នាក់(ស្រី ៥នាក់)
  - ករណីបើកបរក្រោមឥទ្ធិពល ៤ករណី ឃាត់ខ្លួន ៨នាក់
  - ករណីប្រើប្រាស់ ២.៤២៥ករណី ឃាត់ខ្លួន ៧.៧១៥នាក់(ស្រី៤២៧នាក់)
- ឃាត់ខ្លួនជនសង្ស័យចំនួន **១៥.០៥៤ នាក់**(ស្រី ១.០២២ នាក់)/(នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១៣.៤៥២ នាក់) ច្រើនជាង ១.៦០២ នាក់ **កើនលើស ១២%** រួមមាន៖ ជនសង្ស័យជាជនជាតិខ្មែរចំនួន **១៤.១៦៥ នាក់** (ស្រី ៩១៤ នាក់) និងជនបរទេសចំនួន **៨៨៩ នាក់**(ស្រី ១០៨ នាក់) មាន ២០ជនជាតិ រួមមាន ចិន ៤៥៨នាក់(ស្រី១១នាក់)ក្នុងនោះមានចិនតៃវ៉ាន់ ៣៥នាក់ វៀតណាម ២៤៦នាក់(ស្រី ៥៤នាក់) ថៃ ៦១នាក់(ស្រី ៣១នាក់) ឥណ្ឌូនេស៊ី ៤៧នាក់(ស្រី ២នាក់) ឥណ្ឌា ២១នាក់ ឡាវ ៩នាក់(ស្រី ៨នាក់) ម៉ាឡេស៊ី ៨នាក់ ប៉ាគីស្ថាន ៥នាក់ បង់ក្លាដេស ៥នាក់ សាធារណរដ្ឋកូរ៉េ ៤នាក់ មីយ៉ាន់ម៉ា ៤នាក់(ស្រី ២នាក់) នេប៉ាល់ ៤នាក់ តួកគី ៤នាក់ ប៊ូតាន ៣នាក់ នីហ្សេរីយ៉ា ៣នាក់ អង់គ្លេស ២នាក់ តួកម៉េនីស្ថាន ២នាក់ អាម៉េរិក ១នាក់ បារាំង ១នាក់ និងស៊ុយអែត ១នាក់
- ចាប់យកបានគ្រឿងញៀន **២ តោន ៤៤៥ គ.ក្រ ៨៩១,៩៩ ក្រាម** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១ តោន ៨៩០ គ.ក្រ ៨៣១,៤៩ ក្រាម) ច្រើនជាង ៥៥៥ គ.ក្រ ០៦០,៥ ក្រាម **កើនលើស ២៩,៣%**
- ចាប់យកកញ្ឆាក្រៀម **១០៥ គ.ក្រ ៣៨៤,៩៧ ក្រាម**
- សារជាតុគីមីផ្សំដែលរឹបអូសបានចំនួន **២ តោន ១៨៩,១៩ គ.ក្រ** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១៩ តោន ១២៩,៣៥ គ.ក្រ) តិចជាង ១៦ តោន ៩៤០,១៦ គ.ក្រ **ថយចុះ ៨៨,៥%**
- ចាប់យកសម្ភារក្នុងប្រតិបត្តិការបង្ក្រាប រួមមាន រថយន្ត ១១៩ គ្រឿង ម៉ូតូ ១.៥៨០ គ្រឿង ទូរស័ព្ទ ៧.២២០ គ្រឿង ជញ្ជីង ៦៦៥ គ្រឿង អាវុធវែង ៥៤ ដើម អាវុធខ្លី ១៨ ដើម និងរូបិយវត្ថុជាតិ រូបិយប័ណ្ណអន្តរជាតិ រួមមាន ១៣.៣៦១.៩០០ រៀល ១៧.៩៧២ ដុល្លារ ១៩៥.២៤០ បាត និង ១.៤០០.០០០ ដុង
- ចាប់ខ្លួនជនសង្ស័យតាមដីកា មាន ៦២៨ ដីកា ចាប់ខ្លួនចំនួន ៣៨៦ នាក់(ស្រី ១១ នាក់)។

ទន្ទឹមនេះ ចំនួនសរុបនៃលទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងឆមាសទី១ឆ្នាំ២០២៦ មាន៖

- **បទល្មើសគ្រឿងញៀនធំៗ ចាប់ពី១គ.ក្រឡើង** បង្ក្រាបបាន **៧៣ ករណី** (ចោទពីបទល្មើសសម្អាតប្រាក់ **១៣ ករណី**)/(នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន **៧៤ ករណី**) តិចជាង ១ ករណី **ថយចុះ ១,៣៥%**។

[1] បទល្មើស ជនសង្ស័យ វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិ យកតាមតារាងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឃាត់ខ្លួនជនសង្ស័យ **២៣១ នាក់** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ២៣០ នាក់) ច្រើនជាង ១ នាក់ **កើនលើស ០,៤៣%**។ ចាប់យកគ្រឿងញៀន **២ តោន ៣៥៦ គ.ក្រ ក្រាម** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ១ តោន ៨២៨ គ.ក្រ) ច្រើនជាង ៥២៨ គ.ក្រ **កើនលើស ២៨,៨%** ក្នុងនោះមានការចរាចរឆ្លងកាត់ចូលតាមៈ

- ច្រកព្រំដែនគោក បង្ក្រាបបាន **១៧ ករណី** ចាប់យកគ្រឿងញៀន **១ តោន ៩៩៦ គ.ក្រ ២៧៧,៦ ក្រាម** ប្រមាណ **៨៤,៦៣%** មានជាអាទិ៍ៈ ករណីមានប្រភពពីតំបន់ត្រីកោណមាសចរាចរឆ្លងកាត់តាមច្រកព្រំដែនឡាវ បង្ក្រាបបាន **១៦ ករណី** ចាប់យកបានគ្រឿងញៀន **១ តោន ៩៩០ គ.ក្រ ៧៦១,៩៣ ក្រាម** ប្រមាណ **៨៤,៤%** និងករណីមានប្រភពពីតំបន់ត្រីកោណមាស ចរាចរឆ្លងកាត់តាមច្រកព្រំដែនថៃ បង្ក្រាបបាន **១ ករណី** ចាប់យកបានគ្រឿងញៀន **៥ គ.ក្រ ៥១៥,៦៧ ក្រាម** ប្រមាណ **០,២៣%**
- ប្រៃសណីយ៍ បង្ក្រាប ៤ **ករណី** ចាប់យកគ្រឿងញៀន **៥ គ.ក្រ ២០៤,៣៥ ក្រាម** ប្រមាណ **០,២២%**រួមទាំងករណីកែច្នៃផលិតក្នុងស្រុកបង្ក្រាប **១២ ករណី** ចាប់យកគ្រឿងញៀន **១៧៩ គ.ក្រ ០៧២,៤៤ ក្រាម** ប្រមាណ **៧,៦០%** និងករណីរក្សាទុក ជួញដូរ ចាត់ចែង សម្រួលឱ្យប្រើប្រាស់ បង្ក្រាប **៤០ ករណី** ចាប់យកគ្រឿងញៀន **១៧៧ គ.ក្រ ៦០១,៩៥ ក្រាម** ប្រមាណ **៧,៥៤%**។

– បទល្មើសមធ្យមចំនួន **៧២៧ ករណី** (បង្ក្រាបចាប់ពី១០០ក្រាម ដល់៩៩៩ក្រាម) ឃាត់ខ្លួនជនសង្ស័យ **២.០៤១ នាក់**

– បទល្មើសតូចតាច ចំនួន **៤.៩១៤ ករណី**(បង្ក្រាបចាប់ពី៩៩ក្រាមចុះ) ឃាត់ខ្លួនជនសង្ស័យ **១២.៧៨២ នាក់**។ (**មានលម្អិតក្នុងឧបសម្ព័ន្ធទី៧**)

ជាមួយគ្នានេះ តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug បាននិងកំពុងបំផុស និងជំរុញការផ្សព្វផ្សាយឱ្យទាញយកមកប្រើប្រាស់ ដែលមកដល់បច្ចុប្បន្ននេះ មានអ្នកទាញយកចំនួន **៩៨.៥៤០ នាក់**។ ជាក់ស្តែងក្នុងឆមាសទី១ឆ្នាំ២០២៦នេះ អនុគណៈកម្មការប្រចាំបញ្ជា២៤/៧ នៃគណៈកម្មការគ្រប់គ្រងកម្មវិធីទូរស័ព្ទដៃ NoDrug បានទទួលរបាយការណ៍ សរុប **៨.៦៩៨ ករណី** ក្នុងនោះ ដោះស្រាយរួច **៧.៧៣៨ ករណី** កំពុងដោះស្រាយ **៥៧ ករណី** ព័ត៌មានមិនត្រឹមត្រូវ **៣០១ ករណី** សាកល្បង **២៦ ករណី** ព័ត៌មានផ្សេងៗ **៣៨៧ ករណី** និងព័ត៌មានដដែល **១៨៩ ករណី**។

ក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត បានដុតបំផ្លាញគ្រឿងញៀននិងសារធាតុពាក់ព័ន្ធសរុបចំនួន **១១ តោន ៨០៧ គីឡូក្រាម ០៤១,៣៥ ក្រាម**។ ជាមួយគ្នានេះ សារធាតុគីមីផ្សំ និងសារធាតុគីមីមានគ្រោះថ្នាក់ចំនួន **២៣ តោន ៣៦៤ គីឡូក្រាម ៤៥៤ ក្រាម** ត្រៀមធ្វើការបន្សាបនិងបំផ្លាញចោលដោយសុវត្ថិភាពតាមបច្ចេកទេសវិទ្យាសាស្ត្រ។ (**លម្អិតក្នុងឧបសម្ព័ន្ធលេខ៨**)

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **៥.៥៣១ លើក** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៧៧២ លើក) ច្រើនជាង ៤.៧៥៩ លើក **កើនលើស ៦១៦,៤៥%** ក្នុងនោះៈ

– ចុះអប់រំទីតាំងអាជីវកម្មបាន **៤.៥១២ លើក** ស្មើ៦គោលដៅ(សណ្ឋាគារ ១៤លើក ផ្ទះសំណាក់ ២៩៥លើក ផ្ទះជួល ៤.០០៥លើក បារ ១០លើក ខេធីវី ១៧១លើក និងក្លឹប ១៧លើក)

– អញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំ **១.០១៩ លើក** អ្នកចូលរួម **៤៨.៣២៦ នាក់**(ស្រី ២៤.៤២៣នាក់)

– ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចុះធ្វើតេស្តរហ័សរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **៥៧៨ លើក** លើមុខសញ្ញាចំនួន **៣.៥៤១ នាក់** រកឃើញវិជ្ជមានសារធាតុញៀន **៨១២ នាក់** បានបញ្ជូនទៅបន្សាបព្យាបាល។ (**មានលម្អិតក្នុងតារាងឧបសម្ព័ន្ធទី៩**)

៣.៤. ចំណាត់ការរឿងក្តីគ្រឿងញៀនរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត

ក្នុងឆមាសទី១ឆ្នាំ២០២៦នេះ ចំណាត់ការរឿងក្តីលើសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត មានសំណុំរឿង (ដំណាក់កាលអយ្យការ ១.៨៧២ រឿង ដំណាក់កាលស៊ើបសួរ ២.៩១១ រឿង និងដំណាក់កាលជំនុំជម្រះ ២.១៧២ រឿង) សរុបទាំងអស់ចំនួន **៦.៩៥៥ រឿង** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៧.២០៧ រឿង) តិចជាង ២៥២ រឿង **ថយចុះ ៣,៥០%**។(មានលម្អិតក្នុងឧបសម្ព័ន្ធទី១)

៣.៥. លទ្ធផលការងាររបស់មន្ទីរពិសោធន៍គ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀននៃ អ.ជ.ប.គ.ញ. បានសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីចុះធ្វើការពិនិត្យ វិភាគ សន្និដ្ឋាន វាយតម្លៃតាមលក្ខណៈបច្ចេកទេសវិទ្យាសាស្ត្រលើរាល់សារធាតុសង្ស័យ ក៏ដូចជាការដកយក និងទទួលយកសំណាកជាវត្ថុតាងសង្ស័យជាគ្រឿងញៀន ទៅធ្វើកោសល្យវិច័យក្នុងដំណើររឿងនៃបទល្មើសកែច្នៃផលិត រក្សាទុក ដឹកជញ្ជូន ជួញដូរគ្រឿងញៀន និងសារធាតុគីមីផ្សំ រួមទាំងបានរៀបចំ និងចូលរួមក្នុងសកម្មភាពការងារផ្សេងទៀត ជាពិសេសមានសមត្ថភាព និងលទ្ធភាពផលិតឧបករណ៍តេស្តដំហានដំបូងសម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀន ដោយមានលទ្ធផលដូចខាងក្រោម៖

– ធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងសង្ស័យគ្រឿងញៀនចំនួន **៦.៣៧៥ សំណាក** ស្មើនឹង **៣.៦១៨ ករណី** ក្នុងនោះ សំណាកវិជ្ជមានសារធាតុញៀន **៦.០៤៩ សំណាក** ស្មើនឹង **៩៤,៩៣%** និងសំណាកអវិជ្ជមានសារធាតុញៀន **៣២៦ សំណាក** ស្មើនឹង **៥,០៧%**

– ចូលរួមកិច្ចប្រជុំ ស្តីពីគំនិតផ្តួចផ្តើមរួមរបស់ UNODC-UNIDO ដើម្បីពង្រឹងការអភិវឌ្ឍឧស្សាហកម្មឱសថ ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ

– ចុះប្រមូល វេចខ្ចប់ និងដឹកជញ្ជូនសារធាតុគីមីនិងសារធាតុគីមីផ្សំ ដែលស្ថាប័នតុលាការសម្រេចរឹបអូស និងប្រគល់មកគណៈកម្មការដុតបំផ្លាញគ្រឿងញៀន ចំនួនប្រមាណ **៣៣ តោន** សារធាតុគីមីទាំងនេះត្រូវបានវេចខ្ចប់ និងដឹកជញ្ជូនទៅរក្សាទុកនៅឃ្លាំងសុវត្ថិភាព នៅខេត្តកំពង់ស្ពឺ ដើម្បីរង់ចាំធ្វើការបន្សាបនិងបំផ្លាញចោលដោយសុវត្ថិភាពតាមបច្ចេកទេសវិទ្យាសាស្ត្រ

– ផ្តល់ជូនរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធនូវសម្ភារ ឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀន និងឧបករណ៍តេស្តហ័សរកសារធាតុញៀនក្នុងទឹកមូត្រ។ (**ដូចមានក្នុងតារាងឧបសម្ព័ន្ធទី១០**)

– មានសមត្ថភាពនិងលទ្ធភាពផលិតតេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនដំហានដំបូង ប្រភេទម៉ាគ្គីតេស្ត (Marquis test) ចំនួន **១០.៤១០តេស្ត** និងកេតាមីនតេស្ត (Ketamine test) ចំនួន **៣.៦៥០តេស្ត**។

## ៤. ការត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ

ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពគ្រប់គ្រង និងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ក្នុងគោលដៅបង្ការ និងទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់យកទៅកែច្នៃផលិតគ្រឿងញៀនខុសច្បាប់ យើងបានអនុវត្តនូវសកម្មភាពជាក់ស្តែងមួយចំនួនដូចខាងក្រោម៖

– ឯកឧត្តម ទេសរដ្ឋមន្ត្រី ព្រុំ សុខា អនុប្រធានប្រចាំការ អ.ជ.ប.គ.ញ. និងជាប្រធានក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំរបស់រាជរដ្ឋាភិបាល បានអញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា ស្តីពីការពង្រឹងប្រសិទ្ធភាពកិច្ចសហការគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន រោងចក្រ ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរយកទៅផលិតគ្រឿងញៀនខុសច្បាប់

– ចូលរួមកិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពតំបន់ និងការវាយតម្លៃ ការគំរាមកំហែងនៅតំបន់អាស៊ីអាគ្នេយ៍ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ(INCB) តាមប្រព័ន្ធអនឡាញ

– ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការចែករំលែកព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងឧប្បត្តិហេតុសារធាតុគីមីផ្សំ(PICS) និងកំណត់អត្តសញ្ញាណសារធាតុគីមីផ្សំ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ(SINCB) តាមប្រព័ន្ធអនឡាញ

– ប្រជុំផ្សព្វផ្សាយ និងចុះពង្រឹងយន្តការសម្រាប់ការគ្រប់គ្រងត្រួតពិនិត្យការប្រើប្រាស់ ការដឹកជញ្ជូនសារធាតុញៀន និងសារធាតុគីមីផ្សំឆ្លងកាត់ព្រំដែន ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តគោលដៅចំនួន៥ អង្គភាពគយនិងរដ្ឋាករច្រកទ្វារព្រំដែនអន្តរជាតិចំនួន៦ការិយាល័យ និងក្រុមហ៊ុនចំនួន៦ **(មានលម្អិតក្នុងឧបសម្ព័ន្ធទី៦)**

– ក្រសួង ស្ថាប័នជំនាញ បានណែនាំដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំ ស្ថិតក្រោមច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ណែនាំ និងត្រូវមានអ្នកជំនាញផ្នែកគីមីទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងនិងការប្រើប្រាស់សារធាតុគីមីផ្សំសម្រាប់ចង្វាក់ផលិតកម្មរបស់ខ្លួន

– ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណអនុញ្ញាតដល់ក្រុមហ៊ុន រោងចក្រ សហគ្រាសក្នុងការនាំចូលនូវសារធាតុញៀននិងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនសរុបចំនួន **៨០.៨២៨ តោន ៦២៧ គ.ក្រ** (នៅឆមាសទី១ឆ្នាំ២០២៥ មានចំនួន ៧៤.១៥៩ តោន ២២០ គ.ក្រ) ច្រើនជាង ៦.៦៦៩ តោន ៤០៧ គ.ក្រ **កើនលើស ៩,៩៣%។ (មានលម្អិតក្នុងឧបសម្ព័ន្ធទី១១)**

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការ សម្របសម្រួល និងអនុវត្តការងារក្នុងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន ដូចខាងក្រោម៖

– ចូលរួមសហការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសជាប់ព្រំដែន សំដៅពង្រឹងប្រសិទ្ធភាពការងារដែលបានព្រមព្រៀងគ្នាកន្លងមក

– ចូលរួមអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គសម្រាប់ប្រទេសចំនួន៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន

– សហការជាមួយភាគីពាក់ព័ន្ធ ចូលរួមអនុវត្តផែនការប្រតិបត្តិការគម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Project) ឆ្នាំ២០២៣-២០២៧។**(មានលម្អិតក្នុងឧបសម្ព័ន្ធទី៦)**

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន សំដៅធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ដែលរួមមានការងារសំខាន់ៗដូចខាងក្រោម៖

– ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃ អ.ជ.ប.គ.ញ. បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបិទកិច្ចប្រតិបត្តិការរួមនៃគម្រោងសុវត្ថិភាពទន្លេមេគង្គ(SMCC)ឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញ និងអនុញ្ញាតឱ្យលោក David Lking និងក្រុមការងាររដ្ឋបាលប្រឆាំងគ្រឿងញៀនសហរដ្ឋអាម៉េរិកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– កិច្ចប្រជុំមន្ត្រីទំនាក់ទំនងនៃប្រទេសហត្ថលេខី ស្តីពីការគ្រប់គ្រងគ្រឿងញៀន នៅក្នុងមហាអនុតំបន់ទន្លេមេគង្គឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំលើកទី៦៩ នៃគណៈកម្មការទទួលបន្ទុកគ្រឿងញៀន (Commission on Narcotic Drugs) និងព្រឹត្តិការណ៍អម(Side Event) ក្រោមប្រធានបទ «គ្រួសាររឹងមាំ» «Strong Families» ដែលរៀបចំដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម(UNODC) តាមប្រព័ន្ធអនឡាញ

– ផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការត្រីភាគីកម្ពុជា-វៀតណាម-ឡាវ-ម៉ាឡេស៊ី-ឥណ្ឌូនេស៊ី និងសេចក្តីព្រាងផែនការសកម្មភាពអាស៊ាន-ចក្រភពអង់គ្លេស ជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

– ផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាពតំបន់ត្រីកោណមាសឆ្នាំ២០២៦-២០២៧ ក្រោមផែនការប្រតិបត្តិការរួមនៃគម្រោងសុវត្ថិភាពទន្លេមេគង្គ(២០២៣-២០២៧) សម្រាប់ការត្រួតពិនិត្យគ្រឿងញៀនក្នុងចំណោមប្រទេសទាំង៦នៃមហាអនុតំបន់ទន្លេមេគង្គ

ក្រៅពីនោះ ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ អគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.គ.ញ. បានសហការសម្របសម្រួលក្នុងការរៀបចំចាត់បញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញទៅចូលរួមក្នុងសកម្មភាពការងារជាច្រើនផ្សេងទៀត។(**មានលម្អិតក្នុងឧបសម្ព័ន្ធទី៦**)

## ៧. ការពង្រឹងយន្តការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធទាំងអស់ បានពង្រឹងយន្តការជាសេនាធិការក្នុងការអនុវត្តនិងដឹកនាំការងារពហុវិស័យសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះមានសកម្មភាពសំខាន់ៗជាអាទិ៍៖

– បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី៥-៦ ខែមីនា ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅសណ្ឋាគារស៊ីដង់សុខាភ្នំពេញ

– បាននិងកំពុងជំរុញដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយគិតចាប់ពីថ្ងៃដំណើរការមកដល់បច្ចុប្បន្ននេះ មានមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន **១៤៥.១០២ នាក់** បានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀន **ចំនួន ១១២ នាក់** ត្រូវបណ្តេញចេញពីក្របខ័ណ្ឌចំនួន **១០៩ នាក់** និងកំពុងបន្តនីតិវិធី **៣ នាក់**។ ដោយឡែក ក្នុងឆមាសទី១ឆ្នាំ២០២៦នេះ ចំនួន **១៣.៦២៩ នាក់** បានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀន ចំនួន **៩ នាក់** ត្រូវបណ្តេញចេញពីក្របខ័ណ្ឌចំនួន **៦ នាក់** និងកំពុងបន្តនីតិវិធី **៣ នាក់**។(**មានតារាងទិន្នន័យលម្អិតជូនភ្ជាប់មកជាមួយ**)

– បាននិងកំពុងចូលរួមអនុវត្តដំណើរការអង្កេត ស្តីពីការយល់ឃើញលើបញ្ហាគ្រឿងញៀនរបស់ប្រជាពលរដ្ឋ

– ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០២៤-២០២៨

– ជំរុញការអនុវត្តផែនការ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១

ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងជាច្រើនផ្សេងទៀតលើវិស័យដែលពាក់ព័ន្ធ។ (**មានលម្អិតក្នុងឧបសម្ព័ន្ធទី៦**)

### ៨. មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

– ក្រសួងយុត្តិធម៌ បានធ្វើអន្តរាគមន៍ដើម្បីជំរុញដល់ស្ថាប័នអយ្យការ និងតុលាការគ្រប់ជាន់ថ្នាក់ ឱ្យខិតខំប្រមូលគ្រប់គ្រងទ្រព្យសម្បត្តិ មធ្យោបាយ និងសម្ភារដែលបានរឹបអូសក្នុងបទល្មើសគ្រឿងញៀន

– ក្រុមការងាររបស់ក្រសួងយុត្តិធម៌ និងគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន បានចុះពិនិត្យ និងប្រមូលវត្ថុតាងបទល្មើសគ្រឿងញៀន ដែលត្រូវរឹបអូសតាមសាលក្រម និងសាលដីកាស្ថាពរ ដើម្បីវាយតម្លៃប្រកាសលក់ឡាយឡុង

– ក្រុមការងាររបស់ក្រសួងយុត្តិធម៌ ជាសមាជិកគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ទទួលបន្ទុកអនុវត្តសាលក្រម និងសាលដីកាស្ថាពរបានមួយចំនួន។ (**មានលម្អិតក្នុងឧបសម្ព័ន្ធទី១**)

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ដោយបានឆ្លងកាត់ការអនុវត្តការងារអស់រយៈពេលមួយឆមាសទី១ឆ្នាំ២០២៦កន្លងមកនេះ យើងដកពិសោធបាននូវចំណុចខ្លាំង បញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួនដូចខាងក្រោមៈ

### ក. ចំណុចខ្លាំង

១. ការទទួលបាននូវអនុសាសន៍ដឹកនាំ និងការណែនាំបង្ហាញផ្លូវយ៉ាងមុតស្រួចរបស់ **សម្តេចធិបតី** ប្រមុខរាជរដ្ឋាភិបាល ក្នុងការបង្កើតជាចលនាជាតិ និងស្មារតីរួមគ្នាជាធ្លុងមួយនៅទូទាំងប្រទេស ដោយបាន**ចាត់ទុកបញ្ហាគ្រឿងញៀន ជាបញ្ហារួមដែលត្រូវចូលរួមដោះស្រាយទាំងអស់គ្នា** ក្នុងនោះ ការចលនាជំរុញការលើកកម្ពស់ផ្សព្វផ្សាយអប់រំ ការចុះអនុស្សរណៈនៃការយោគយល់ជាមួយគ្រប់វិស័យ និងការបញ្ជ្រាបការអប់រំ បង្ការទប់ស្កាត់ពីវិនាសកម្មនៃគ្រឿងញៀន បានធ្វើឱ្យប្រជាពលរដ្ឋនិងសង្គមជាតិទាំងមូល ចូលរួមគ្រប់សកម្មភាព ដើម្បីកម្ចាត់គ្រឿងញៀនចេញពីសង្គមកម្ពុជា។

២. ការបំពេញតួនាទីយ៉ាងល្អប្រសើររបស់ថ្នាក់ដឹកនាំនិងសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើឱ្យបេសកកម្មដ៏មានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន កំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវឆ្ពោះទៅសម្រេចបានគោលដៅ **«គ្រឿងញៀននឹងលែងជាឧបសគ្គដល់កិច្ចអភិវឌ្ឍជាតិ»**។

៣. ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់បានម៉ឺងម៉ាត់និងតឹងរ៉ឹងរបស់ស្ថាប័នអនុវត្តច្បាប់ បានធ្វើឱ្យការប្រើប្រាស់គ្រឿងញៀន នៅក្នុងសហគមន៍មានការថយចុះ ជាពិសេសការប្រើប្រាស់តាមក្លឹបកម្សាន្តតាមមូលដ្ឋាន និងការលបលាក់កែច្នៃផលិត ត្រូវបានលុបបំបាត់បន្តិចៗម្តង រួមទាំងការចាត់វិធានការជំនាញគួបផ្សំបទពិសោធក្នុងការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀនរបស់មន្ត្រីអនុវត្តច្បាប់ ដោយបានឃាត់ខ្លួនជនសង្ស័យជាច្រើននាក់ និងឈានទៅចាប់ខ្លួនមេខ្លោង រួមទាំងបណ្តាញខ្សែរយៈជាបន្តបន្ទាប់យកមកផ្តន្ទាទោសតាមច្បាប់។

៤. ការធ្វើបរិវត្តកម្មឌីជីថល ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយក្នុងនោះ បានបង្កើតកម្មវិធីទូរស័ព្ទដៃ NoDrug សម្រាប់ឱ្យពលរដ្ឋទទួលបានការកម្សាន្ត បែបអប់រំ មេរៀន ព័ត៌មាននានា ពាក់ព័ន្ធនឹងប្រធានបទគ្រឿងញៀន ព្រមទាំងជាមធ្យោបាយរាយការណ៍ ២៤ ម៉ោង សម្ងាត់និងមានសុវត្ថិភាព។

៥. ការបង្កើតថ្នាលឌីជីថល សម្រាប់ផ្ទុកទិន្នន័យអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទា សម្រាប់តាមដានប្រសិទ្ធភាពនៃការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទិន្នន័យច្បាស់លាស់សម្រាប់រៀបចំផែនការធ្វើសមាហរណកម្ម ដើម្បីស្តារនិងកសាងធនធានមនុស្សឡើងវិញសម្រាប់សង្គមជាតិ។

៦. ការលើកកម្ពស់អភិបាលកិច្ចតាមរយៈការអនុវត្តគោលការណ៍ **«សម្អាតផ្ទះយើង»** និងគោលការណ៍ **«សម្អាតចកចេញពីផ្ទៃបឹង»** ដើម្បីរក្សាបានផ្ទៃបឹងដ៏ស្អាតថ្លាមួយក្នុងស្ថាប័នរដ្ឋ ដូចជាការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ដើម្បីធ្វើតេស្តត្រួតពិនិត្យជាប់ជាប្រចាំរកសារធាតុញៀនលើមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្ហាញជាសក្ខីភាពនៃវិធានការក្តៅរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាភាពស្អាតស្អំក្នុងស្ថាប័នរដ្ឋ និងភាពជាគំរូនៃការអនុវត្តច្បាប់។

៧. ការទទួលស្គាល់ លើកសរសើរ និងវាយតម្លៃខ្ពស់ពីសំណាក់សហគមន៍អន្តរជាតិ អំពីយន្តការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ប្រកបដោយកម្លាំងចលករ និងបរិយាបន្នគ្រប់វិស័យ ក៏ដូចជាការកៀរគរគ្រប់វិស័យ ឯកជន ដៃគូ អង្គការជាតិ និងអន្តរជាតិ ចូលរួមជាមួយអាជ្ញាធរក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**ខ. បញ្ហាប្រឈម និងចំណុចខ្វះខាត**

ទោះបីជា អ.ជ.ប.គ.ញ. សម្រេចបានលទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈម និងចំណុចខ្វះខាតដូចខាងក្រោមៈ

១. ក្នុងស្ថានការណ៍ដែលមានហានិភ័យខ្ពស់ មានភាពផុយស្រួយមិនប្រាកដប្រជាលើផ្ទៃអន្តរជាតិ ដូចជាសង្គ្រាមនៅអ៊ុយក្រែន នៅមជ្ឈិមបូព៌ា និងជម្លោះប្រដាប់អាវុធនៅតាមតំបន់ផងនោះ ពិភពលោកទាំងមូលក៏នៅតែបន្តប្រឈមទៅនឹងកំណើននៃការដាំដុះ ការផលិត ការចម្រាញ់ ការចរាចរ ការរក្សាទុក ការជួញដូរ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ រួមទាំងការលួចបង្វែរសារធាតុគីមីផ្សំយកទៅផលិតសារធាតុញៀន បាននិងកំពុងបន្តរីករាលដាលគួរឱ្យគត់សម្គាល់។

២. ការអនុវត្តការកិច្ចមិនបានម៉ឺងម៉ាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ទាំងក្នុងជួរកម្លាំងប្រតិបត្តិការបង្ក្រាបគ្រឿងញៀន ទាំងនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដែលធ្វើឱ្យលំហូរចូលគ្រឿងញៀនមកក្នុងប្រទេស ក្នុងបរិមាណដ៏ច្រើន ជាពិសេសការលួចនាំចូលគ្រឿងញៀនតាមច្រកផ្លូវគោក(ភាគច្រើនភូមិភាគឦសាន)នៅតែបន្តកើតមាន មិនទាន់អាចកាត់បន្ថយ និងឈានទៅលុបបំបាត់បាននៅឡើយ។

៣. ការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបរបស់អង្គភាព ស្ថាប័នមានសមត្ថកិច្ច ទៅលើក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង មានបណ្តាញរឹងមាំទូទាំងសកលលោក នៅមានកម្រិត ដោយសារកិច្ចសហប្រតិបត្តិការអន្តរជាតិពុំបានទូលំទូលាយ និងស៊ីជម្រៅ ដែលពុំអាចបង្ក្រាបបានដល់ឫសគល់ និងចំមេក្លោងធំនៅក្រៅប្រទេសនៅឡើយ រួមទាំងការនៅពុំទាន់មានភាពរឹងមាំរបស់កងកម្លាំងក្នុងការអនុវត្តជំនាញ និងច្បាប់ឱ្យឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃបញ្ហាគ្រឿងញៀន។

៤. ការចាត់វិធានការបង្ការ ទប់ស្កាត់ តាមរយៈការងារផ្សព្វផ្សាយ អប់រំ នៅក្នុងព្រឹត្តិការណ៍នានាដែលរៀបចំដោយក្រសួង ស្ថាប័ន ក៏ដូចជាអាជ្ញាធរមូលដ្ឋាន ពុំទាន់មានការបញ្ជ្រាបការប្រយុទ្ធប្រឆាំងគ្រឿងញៀន ឱ្យបានទូលំទូលាយ និងស៊ីជម្រៅ ហើយអង្គភាពពាក់ព័ន្ធមួយចំនួន ពុំទាន់ម្ចាស់ការ ជួយក្នុងការងារផលិតមាតិកាផ្សព្វផ្សាយអប់រំប្រយុទ្ធប្រឆាំងគ្រឿងញៀន ឱ្យបានពេញលេញនៅឡើយ។

៥. ប្រសិទ្ធភាពនៃការបន្សាបព្យាបាល ពុំទាន់មានការវិវឌ្ឍប្រសើរឡើងនៅឡើយ ដោយមិនទាន់មានឱសថព្យាបាល ឬវិធីបន្សាបព្យាបាលថ្មីណាមួយ ដែលអាចឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន រួមនឹងចំនួនមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដែលមានគុណភាពស្តង់ដា នៅមានចំនួនតិចនៅឡើយ បើប្រៀបធៀបជាមួយនឹងចំនួនអ្នកញៀនគ្រឿងញៀន ដែលមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ។

៦. ការចូលរួមអនុវត្តការកិច្ចនៅក្នុងយន្តការគ្រប់គ្រង និងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំរបស់ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធនៅមានកម្រិត មានភាពខ្វះចន្លោះច្រើន មិនទាន់ឆ្លើយតបបានទៅនឹងសំណូមពរការងារ។

## IV. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ឆមាសទី២ ឆ្នាំ២០២៦

ផ្អែកតាមការសន្និដ្ឋាន និងវាយតម្លៃខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន សមាជិកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានប្តេជ្ញាយកចិត្តទុកដាក់ក្នុងការអនុវត្តបន្ថែមឱ្យកាន់តែមានប្រសិទ្ធភាពនូវចំណុចដែលអនុវត្តមិនបានពេញលេញ ដោយបានដាក់ចេញនូវទិសដៅការងារសម្រាប់បន្តអនុវត្តក្នុងឆមាសទី២ឆ្នាំ២០២៦ ដូចខាងក្រោមៈ

### ១. ការផ្សព្វផ្សាយអប់រំ

១.១ បន្តជំរុញ និងបំផុសឱ្យមានជាចលនាជាតិ និងស្មារតីរួមទូទាំងប្រទេសក្នុងការងារផ្សព្វផ្សាយ អប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដោយបន្តចាត់ទុកបញ្ហាគ្រឿងញៀន ជាបញ្ហារួមដែលត្រូវចូលរួមដោះស្រាយទាំងអស់គ្នា រួមគ្នាប្រែក្លាយឱ្យទៅជាទំនៀមទម្លាប់ដ៏ល្អប្រពៃមួយ ដោយផ្តើមចេញពីបុគ្គលម្នាក់ គ្រួសារមួយ រហូតដល់ក្នុងសហគមន៍ទាំងមូល។

១.២ បន្តកៀរគរឱ្យមានការចូលរួមពីគ្រប់វិស័យ ជាពិសេសវិស័យដែលមានឥទ្ធិពល ដូចជា សិល្បៈ កីឡា សាសនា ទេសចរណ៍ និងកម្សាន្ត ដើម្បីបញ្ជ្រាបការយល់ដឹងអំពីផលប៉ះពាល់ និងវិនាសកម្មនៃគ្រឿងញៀន សំដៅធ្វើយ៉ាងណាឱ្យពលរដ្ឋទាំងមូល ជាពិសេសយុវជន យុវនារី ដែលជាទំពាំងស្នងឫស្សី មានជំនឿខ្លួនឯងថាខ្លួនមិនធ្លាក់ក្នុងអន្លង់នៃគ្រឿងញៀនជាដាច់ខាត។

១.៣ បន្តពង្រឹងយន្តការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅតាមក្រសួង ស្ថាប័នទាំងអស់ ដើម្បីបំផុសឱ្យមានការចូលរួមឱ្យបានសកម្មដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិនាសកម្មនៃគ្រឿងញៀន ដោយបង្កើតវិធីសាស្ត្រផ្សព្វផ្សាយ អប់រំឱ្យមានលក្ខណៈទំនើបទាន់សម័យ និងមានភាពទាក់ទាញខ្ពស់ ព្រមទាំងជំរុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានឱ្យបង្កើនសកម្មភាពផ្សព្វផ្សាយ អប់រំក្នុងមូលដ្ឋានឱ្យបានជាប្រចាំ និងឱ្យចំគោលដៅងាយរងហានិភ័យ។

១.៤ បន្តបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន តាមរយៈវិទ្យុ ទូរទស្សន៍ ភាពយន្ត ទូរស័ព្ទចល័ត Facebook Page ស្លាកផលិតផល វិក្កយបត្រទឹក អគ្គិសនី។ល។ តាមរយៈកម្មវិធីប្រគំតន្ត្រី ការផ្សព្វផ្សាយពាណិជ្ជកម្ម កម្មវិធីបុណ្យជាតិ-អន្តជាតិធំៗ។ល។

### ២. ការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

២.១. បន្តពង្រឹងការអនុវត្តភារកិច្ចជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបន្សាបព្យាបាល ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់អ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលរបស់រដ្ឋ និងឯកជន ជំរុញការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP)សម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននិងសហការបញ្ចូលទិន្នន័យអ្នកញៀនគ្រឿងញៀនតាមមជ្ឈមណ្ឌល ដើម្បីរៀបចំផែនការច្បាស់លាស់សម្រាប់ការធ្វើសមាហរណកម្មចូលក្នុងសង្គម។

២.២. បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ឱ្យពង្រឹង និងបង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ព្យាបាលអ្នកញៀនគ្រឿងញៀន ដើម្បីគាំទ្រឱ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលក្នុងការទៅទទួលយកសេវាព្យាបាលនៅតាមសហគមន៍។

២.៣. បន្តសម្របសម្រួលជាមួយក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ពន្លឿននីតិវិធីក្នុងជួយគម្រោងសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្វាយរៀង។

២.៤. បន្តពង្រឹងនិងលើកកម្ពស់សមត្ថភាពជំនាញដល់មន្ត្រីពាក់ព័ន្ធក្នុងការផ្តល់សេវាព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

៣.១. បន្តពង្រឹងប្រសិទ្ធភាពអនុវត្តច្បាប់ ដើម្បីបង្ការ ទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ទម្រង់ ជាពិសេសការចរាចរគ្រឿងញៀនឆ្លងកាត់ផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍។

៣.២. បង្កើនកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ និងលើកកម្ពស់ក្រមសីលធម៌មន្ត្រីអនុវត្តច្បាប់ ដោយឈរលើគោលការណ៍ ៣ កុំ ១ រាយការណ៍ រួមទាំងការលើកកម្ពស់សមត្ថភាពជំនាញក្នុងការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបសំដៅធ្វើយ៉ាងណាកាត់ផ្តាច់ខ្សែរយៈ និងបំផ្លាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀនឱ្យដល់ឫសគល់ ដើម្បីឈានដល់ការកាត់បន្ថយនិងលុបបំបាត់ការជួញដូរនិងប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍ និងស្របតាមគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព។

៣.៣. អាជ្ញាធរមូលដ្ឋានរាជធានី ខេត្ត បន្តជំរុញដោះស្រាយនិងបង្ក្រាបឱ្យបានទាន់ពេល រាល់ករណីពលរដ្ឋរាយការណ៍ពីករណីគ្រឿងញៀនតាមកម្មវិធីទូរស័ព្ទដៃ NoDrug ដើម្បីបង្កើនទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋមកលើសមត្ថកិច្ច។

៣.៤. បន្តពង្រឹងការអនុវត្តវិធានការរដ្ឋបាល ស្របនឹងវិធានការច្បាប់ នៅតាមគោលដៅស្មុគស្មាញដែលមានហានិភ័យដូចជាផ្ទះសំណាក់ ផ្ទះជួល បន្ទប់ជួល ក្លឹបកម្សាន្ត ខារ៉ាអូខេ ទីតាំងសប្បាយដ្ឋាន និងតំបន់មិនរៀបរយ។ល។ និងបន្តចុះធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រលើក្មេងទំនើង ជនមានតម្រុយប្រើប្រាស់គ្រឿងញៀន និងធ្នក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករនិងដឹកអ្នកដំណើរ។

៣.៥. ពង្រឹងការគ្រប់គ្រងមុខសញ្ញាគ្រឿងញៀនតាមមូលដ្ឋាន ជាពិសេសធ្វើបច្ចុប្បន្នភាពតាមប្រព័ន្ធបច្ចេកវិទ្យា។

៣.៦. ពង្រឹងសកម្មភាពការងាររបស់មន្ទីរពិសោធន៍គ្រឿងញៀន ដោយបន្តពិនិត្យវិភាគសំណាកដែលសង្ស័យជាគ្រឿងញៀន និងផ្តល់លទ្ធផលកោសល្យវិច័យជូនសាលាដំបូងរាជធានី ខេត្ត បានទាន់ពេលវេលា បន្តផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង បន្តកិច្ចសហការធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រជូនមន្ត្រីរាជការ និងកិច្ចសហការជាមួយស្ថាប័នថ្នាក់ជាតិ និងអន្តរជាតិក្នុងការប្រមូល វេចខ្ចប់និងដឹកជញ្ជូនសារធាតុគីមីនិងសារធាតុគីមីផ្សំ ដើម្បីយកទៅរក្សាទុកនៅទីតាំងសុវត្ថិភាព និងរង់ចាំបន្សាបនិងបំផ្លាញចោលដោយសុវត្ថិភាពតាមបច្ចេកទេស។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

៤.១. បន្តពង្រឹងយន្តការក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ។

៤.២. ពង្រឹងនិងជំរុញការអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP) ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ។

៤.៣. បន្តជំរុញក្រសួង ស្ថាប័នមានសមត្ថកិច្ច ណែនាំដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលប្រើប្រាស់សារធាតុគីមីផ្សំ ត្រូវរៀបចំឱ្យមានអ្នកជំនាញគីមីទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់សារធាតុគីមីផ្សំសម្រាប់ផលិតកម្មរបស់ខ្លួន ទាំងលើការទិញលក់ ការប្រើប្រាស់ និងការធ្វើសន្និធិ។

៤.៤. បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការ ទប់ស្កាត់ ការប្រើប្រាស់ទីតាំងទាំងនោះទៅលួចលាក់បង្វែរសារធាតុគីមីផ្សំ ទៅកែច្នៃផលិតគ្រឿងញៀនខុសច្បាប់។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. បន្តចូលរួម និងសហការសម្របសម្រួលអនុវត្តយន្តការកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសជាប់ព្រំដែន។

៥.២. បន្តចូលរួមអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គសម្រាប់ប្រទេសចំនួន៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

៥.៣. ជំរុញការអនុវត្តយន្តការភូមិ ឃុំ សង្កាត់ ស គ្មានគ្រឿងញៀន តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស បំពាក់សម្ភារកិច្ចប្រតិបត្តិការ និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

៥.៤. ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍

៦.១. បន្តអនុវត្តក្នុងភាពជាដៃគូជាមួយបណ្តាប្រទេសនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដើម្បីធានាប្រសិទ្ធភាពអនុវត្តខ្លឹមសារកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។

៦.២. បន្តបង្ហាញពីឆន្ទៈដ៏មុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមវិធានការគន្លឹះទាំង៥នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

៦.៣. បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយប្រទេសក្នុងតំបន់ ព្រមទាំងអន្តរជាតិ ដើម្បីផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលា ចែករំលែកបទពិសោធន៍ និងជំនាញបច្ចេកទេស ក្នុងស្មារតីរួមជាធ្លុងមួយ ធ្វើយ៉ាងណាក្នុងការកាត់ផ្តាច់ចរន្តក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិឆ្លងដែន។

៦.៤. បន្តចូលរួមកិច្ចប្រជុំ និងសម្របសម្រួលអនុវត្តភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បន្តចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់បទបញ្ជា០១បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៧.២. បន្តចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់បទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

៧.៣. ត្រៀមចូលរួមសម្អាតទិន្នន័យបានមកពីដំណើរការអង្កេត ស្តីពីការយល់ឃើញលើបញ្ហាគ្រឿងញៀនរបស់ប្រជាពលរដ្ឋ។

៧.៤. បន្តចូលរួមតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-ឆ្នាំ២០២៨ ផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ផែនការសកម្មភាព២០២៥-២០២៧នៃគោលនយោបាយជាតិប្រជាជន និងគោលនយោបាយអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាសម្រាប់ឆ្នាំ២០១៦-២០៣០។

៧.៥. បន្តសហការរៀបចំផ្តល់ធាតុចូលលើការស្នើសុំបញ្ចូលសារធាតុអេតូមីដាត បារីអេឡិចត្រូនិកសារធាតុញៀនប៉ះពាល់ប្រព័ន្ធប្រសាទ និងសារធាតុគីមីផ្សំចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧.៦. បន្តសហការរៀបចំនិងវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងគ្រឿងញៀន។

៧.៧. ជំរុញការអនុវត្តទិសដៅការងារដែលបានដាក់ចេញសម្រាប់ឆ្នាំ២០២៦ កាលពីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥។

៧.៨. ត្រៀមផ្សព្វផ្សាយផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

## ៨. ការងារមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

៨.១. ពង្រឹងការអនុវត្តស្មារតីអនុក្រឹត្យ ស្តីពីមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ឱ្យស្របតាមច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានសង្គតិភាពជាមួយច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

៨.២. បន្តតាមដានសំណុំរឿងបទល្មើសគ្រឿងញៀន តាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីពន្លឿននីតិវិធីចំណាត់ការរឿងក្តី និងការពន្លាតនីតិវិធីស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសសម្អាតប្រាក់។

៨.៣. សហការជាមួយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីពន្លឿននីតិវិធីចាត់ការរឿងក្តី និងចេញសាលក្រមឬសាលដីកាស្ថាពរ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

៨.៤. ជំរុញសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីប្រមូលសាលក្រមឬសាលដីកាស្ថាពរដែលបានសម្រេចរឹបអូសជាសម្បត្តិរដ្ឋនូវវត្ថុតាង មធ្យោបាយ និងទ្រព្យសម្បត្តិផ្សេងៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជូនគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន។

## ៩. ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

បន្តការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ទៅតាមវិធានការជំនាញទាំង៥ មានជាអាទិ៍ វិធានការអប់រំ វិធានការរដ្ឋបាល វិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម វិធានការអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យកាន់តែសកម្មមានការទទួលខុសត្រូវ ជាពិសេសបង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ឱ្យបានសម្រេចតាមគោលការណ៍ដែលបានកំណត់ និងមានប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

សន្តិបណ្ឌិត.នេត.សាវឿន

**ចម្លងជូន៖**
-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.
"ដើម្បីជូនជ្រាប"
-ក្រសួង-ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ.
-អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ កាលប្បវត្តិ